01302767

លេខ: D191/16/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jul-2016, 13:50
CMS/CFO: Sann Rada

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម ]**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

# ដីកាសម្រេចលើសំណើសុំទទួលបានការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបីជាភាសាអាល្លឺម៉ង់ និងសេចក្តីសម្រេចមួយជាភាសាហូឡង់

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES
ជេត វណ្ណលី
ឡោ ជុនធី
Yiqiang LIU
ស៊ិន ស៊ីវ៉ន
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស")នៅក្នុងសំណុំរឿងនេះបាន ចុះបញ្ជីនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

២. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ខ្ញុំបានអញ្ជើញអ្នកសិក្សាស្រាវជ្រាវ អង្គការសិក្សាស្រាវជ្រាវ និងអង្គការផ្សេងទៀតដែលធ្វើការក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដាក់សារណាមិនមែនជាភាគីថាតើការវាយប្រហារមកលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋ គឺជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលដែរឬទេ("សេចក្តីអំពាវនាវសុំឱ្យដាក់សារណា")[1]។

៣. សារណាមិនមែនជាភាគីចំនួន ១១ បានដាក់មកជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវសុំឱ្យដាក់សារណា[2]។

៤. នៅក្នុងលិខិតមួយចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី មាស មុត ("មេធាវីការពារក្តី") បានស្នើថា ស.ច.ស គួរទទួលបានការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបីជាភាសាអាល្លឺម៉ង់ និងសេចក្តីសម្រេចមួយជាភាសាហូឡង់ដែលបានលើកយោងនៅក្នុងសារណាមិនមែនជាភាគីមួយចំនួនធំ("សំណើ")[3]។

## II. សារណា

៥. មេធាវីការពារក្តី ស្នើថា ស.ច.ស គួរទទួលបានការបកប្រែជាភាសាអង់គ្លេសនៃ*រឿងក្តី R* *រឿងក្តី P និងអ្នកផ្សេងទៀត* និង *រឿងក្តី H* និងរឿងក្តីហូឡង់មួយ គឺ *In re Pilz* ដែលបាន

---

[1] សំណុំរឿង ០០៣ ឯកសារ D191 *សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦។

[2] សូមមើលសំណុំរឿង ០០៣ ឯកសារ D191/3, D191/4, D191/5, D191/6, D191/7, D191/8, D191/9, D191/10, D191/11, D191/12 និង D191/13។

[3] សំណុំរឿង ០០៣ ឯកសារ D191/16 *ស្នើសុំឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត យកការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបីជាភាសាអាល្លឺម៉ង់ពីតុលាការកំពូលនៃតំបន់គ្រប់គ្រងដោយអង់គ្លេស និងសេចក្តីសម្រេចមួយជាភាសាហូឡង់ពីតុលាការកំពូលពិសេស* ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើ")។

លើកយោងនៅក្នុងសារណាចំនួន ៧ ក្នុងចំណោមសារណាមិនមែនជាភាគីចំនួន ១១ ដែលបានដាក់ជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវសុំឲ្យដាក់សារណា[4]។

៦. មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា សម្រាប់ការឆ្លើយតបរបស់ខ្លួនទៅនឹងសារណាមិនមែនជាភាគីទាំងនោះ និងសេចក្តីអំពាវនាវសុំឲ្យដាក់សារណា មេធាវីការពារក្តីចាំបាច់ត្រូវត្រួតពិនិត្យមើលការបកប្រែទាំងស្រុង និងត្រឹមត្រូវជាភាសាអង់គ្លេសនៃសេចក្តីសម្រេចទាំងនេះ មិនមែនត្រឹមតែសេចក្តីសង្ខេបរឿងក្តីជាភាសាអង់គ្លេសឡើយ[5]។ មេធាវីការពារក្តី ក៏កត់សម្គាល់ថាខ្លួនមិនមានបុគ្គលិក ឬកម្មសិក្សាការីដែលអាចអាន ឬនិយាយភាសាអាល្លឺម៉ង់ ឬហូឡង់បានឡើយ ដូច្នេះមេធាវីការពារក្តី ចាញ់ប្រៀបក្នុងការរៀបចំចម្លើយតបរបស់ខ្លួន[6]។

## III. ពិភាក្សា

៧. ខ្ញុំយល់ខ្លះតាមគោលជំហររបស់មេធាវីការពារក្តី ប៉ុន្តែ មេធាវីការពារក្តី មិនមានសិទ្ធិទទួលបានការបកប្រែជាភាសាអង់គ្លេសនៃឯកសារទាំងអស់ដែលបានលើកយោងនៅក្នុងសារណាឡើយតាមច្បាប់កម្ពុជា ឬក៏តាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ បន្ថែមពីលើនេះទៀត សិទ្ធិដាច់ខាតបែបនេះមិនមានឡើយនៅក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(“ICCPR”) ដែលបានបញ្ចូលទៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមរយៈមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរដ្ឋាភិបាលកម្ពុជា និងមាត្រា ៣៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[7]។ សិទ្ធិដែលមានចែងនៅក្នុងមាត្រា១៤ នៃ ICCPR ក៏អនុវត្តផងដែរនៅដំណាក់កាលបុរេជំនុំជម្រះនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក[8]។

---

[4] សំណើ ទំព័រ ១។ រឿងក្តី *R* (StS 19/48) តុលាការកំពូលប្រចាំភូមិភាគកាន់កាប់ដោយអង់គ្លេស ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៤៨។ រឿងក្តី *P និងអ្នកផ្សេងទៀត* (StS 111/48) តុលាការកំពូលប្រចាំតំបន់កាន់កាប់ដោយអង់គ្លេស ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៨។ រឿងក្តី *H និងអ្នកផ្សេងទៀត* (StS 309/49) តុលាការកំពូលប្រចាំតំបន់កាន់កាប់ដោយអង់គ្លេស ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ និង រឿងក្តី *In re Pilz*តុលាការជាន់ខ្ពស់ពិសេស ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៥០។

[5] សំណើ ទំព័រ ១។

[6] ដូចជើងទំព័រខាងលើ។

[7] មាត្រា ៣៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា បានបញ្ចូលយ៉ាងច្បាស់នូវមាត្រា ១៤ នៃកតិកាសញ្ញា ICCPR ដែលកម្ពុជា គឺជាហត្ថលេខី។ មាត្រា ១៤(៣)នៃ ICCPR ចែងថា “*ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន*

៨. មាត្រា ១៤(៣)(ច)នៃ ICCPR មិនផ្តល់សិទ្ធិឲ្យទទួលបានការបកប្រែទាំងស្រុងនូវឯកសារទាំងអស់ឡើយ ដូចបានកំណត់នៅក្នុងរឿងក្តី *Hill និង Hill តទល់នឹងអេស្ប៉ាញ*[9] នៅក្នុងបរិបទមាត្រា ១៤(៣)(ខ)។ ពាក្យបណ្តឹងគឺថា អេស្ប៉ាញ មិនបានផ្តល់ការបកប្រែលើឯកសារមួយចំនួនដែលនឹងជួយមេធាវីការពារក្តី ឲ្យយល់បានកាន់តែប្រសើរអំពីបទចោទ និងរៀបចំការពារក្តីឡើយ។ គណៈកម្មាធិការបានសម្រេចថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនមែនមានន័យថា ចុងចោទដែលមិនយល់ពីភាសាដែលប្រើប្រាស់នៅក្នុងតុលាការ មានសិទ្ធិទទួលបានការបកប្រែឯកសារ*ពាក់ព័ន្ធ*ទាំងអស់នៅក្នុងកិច្ចស៊ើបសួរព្រហ្មទណ្ឌឡើយ ដរាបណា មេធាវីរបស់គាត់អាចទទួលបានឯកសារ*ពាក់ព័ន្ធ*ទាំងនោះ[គូសបញ្ជាក់បន្ថែម]។

៩. យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្តល់ការណែនាំដ៏មានសារៈប្រយោជន៍ទាក់ទងនឹងវិសាលភាពនៃសិទ្ធិដែលបាកលើកយោងនៅក្នុងមាត្រា ១៤(៣)(ក) និង (ច)នៃ ICCPR ដោយពិនិត្យឃើញថា បទប្បញ្ញត្តិទាំងនេះមានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៦(៣)(ក) និង ៦(៣)(ង)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ មាត្រា ៦(៣)(ក)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចែងថា ជនគ្រប់រូបដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិត្រូវជូនព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជនជាប់ចោទចេះ[10]។ ប៉ុន្តែ នៅក្នុងមាត្រា ៦(៣)(ក)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មិនមានសិទ្ធិដែលជនជាប់ចោទត្រូវទទួលបានការបកប្រែទាំងស្រុងនៃសំណុំរឿងតុលាការឡើយ[11]។ មាត្រា ៦(៣)(ក)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស អនុវត្តជាចម្បងចំពោះ

---

*ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ (...) (ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ (...) (ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះនិយាយភាសាដែលប្រើប្រាស់ក្នុងសវនាការ (...)"*។ *សូមមើលផងដែរ* វិធានផ្ទៃក្នុង ២១ ដែលមានបទប្បញ្ញត្តិស្រដៀងគ្នានេះដែរ។

[8] សំណុំរឿង ០០២ ឯកសារ D264/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1)* ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ១៣។

[9] ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៧ UNHRC, 526/1993 កថាខណ្ឌ ១៤.២។

[10] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៦(៣)(ក)។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *X តទល់នឹងអូស្ត្រា (dec)* ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៧១។

[11] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *X តទល់នឹងអូស្ត្រា (dec)* ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៧០។

ការជូនដំណឹង និងការចោទប្រកាន់ជនជាប់ចោទបញ្ជូនទៅជំនុំជម្រះ និងសម្ភារៈឯកសារពាក់ព័ន្ធនានាដូចជា ចម្លើយសាក្សីសំខាន់ៗដែលត្រូវការជាចាំបាច់ដើម្បីយល់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់[12]។

១០. ម្យ៉ាងវិញទៀត មាត្រា ៦(៣)(ង)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចែងថា ជនគ្រប់រូបដែលដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានជំនួយការដោយឥតគិតថ្លៃ ពីអ្នកបកប្រែ ប្រសិនបើគាត់មិនអាចយល់ ឬនិយាយភាសាដែលប្រើប្រាស់នៅក្នុងតុលាការ[13]។ នៅក្នុងយុត្តិសាស្ត្រសង្គតិភាពរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ត្រង់នេះធានាសិទ្ធិទទួលបានជំនួយការដោយឥតគិតថ្លៃពីអ្នកបកប្រែ ដើម្បីបកប្រែជាលាយល័ក្ខណ៍អក្សរ ឬបកប្រែផ្ទាល់មាត់នូវ *"ឯកសារ ឬចម្លើយទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធីដែលចាំបាច់សម្រាប់ជនជាប់ចោទ ត្រូវយល់ ដើម្បីទទួលបានប្រយោជន៍ពីការជំនុំជម្រះដោយយុត្តិធម៌"*[14]។

១១. ប៉ុន្តែ តុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងរឿងក្តី *Kamasinski តទល់នឹងអូស្ត្រា* ក៏បានបញ្ជាក់ថា ការមិនមានការបកប្រែជាលាយល័ក្ខណ៍អក្សរនៃសាលក្រមមិនកំណត់ថាជាការរំលោភមាត្រា ៦(៣)(ង)ឡើយ ហើយបានបញ្ជាក់ទៀតថា *"ជំនួយការផ្នែកបកប្រែភាសាដែលបានផ្តល់ជូន គួរតែជាជំនួយការដើម្បីឲ្យចុងចោទអាចមានចំណេះដឹងអំពីរឿងក្តីចោទគាត់ និងដើម្បីការពារខ្លួនគាត់ ជាពិសេសដោយអាចបង្ហាញរឿងរ៉ាវរបស់គាត់នៅចំពោះមុខតុលាការ"*[15]។

១២. ស្រដៀងគ្នានេះដែរ មាត្រា ៣(១)-(៤)នៃសេចក្តីណែនាំ2010/64/EU របស់សភាអឺរ៉ុប និងក្រុមប្រឹក្សាចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ស្តីពីសិទ្ធិទទួលបានការបកប្រែផ្ទាល់មាត់ និងបកប្រែជាលាយល័ក្ខណ៍អក្សរនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺគ្រាន់តែតម្រូវឲ្យការបកប្រែឯកសារសំខាន់ៗតែប៉ុណ្ណោះ និងមានចែងដូចខាងក្រោម៖

---

[12] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Kamasinski តទល់នឹងអូស្ត្រា* ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៨៩ កថាខណ្ឌ ៧៩។

[13] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៦(៣)(ង)។

[14] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Luedicke, Belkacem និង Koç តទល់នឹងអាល្លឺម៉ង់* ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨ កថាខណ្ឌ ៤៨។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី*Kamasinskiតទល់នឹងអូស្ត្រា* ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៨៩ កថាខណ្ឌ ៧៤។

[15] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Kamasinski តទល់នឹងអូស្ត្រា* ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៨៩ កថាខណ្ឌ ៧៤។

មាត្រា ៣

សិទ្ធិទទួលបានការបកប្រែឯកសារសំខាន់ៗ

១. រដ្ឋជាសមាជិក ត្រូវធានាថា ជនសង្ស័យ ឬជនជាប់ចោទ ដែលមិនយល់ភាសានៅក្នុងដំណើរការនីតិវិធីពាក់ព័ន្ធ ត្រូវផ្តល់ជូនក្នុងរយៈពេលសមហេតុផលនូវការបកប្រែជាលាយល័ក្ខណ៍អក្សរនៃឯកសារទាំងអស់ដែលសំខាន់ដើម្បីធានាថា ជននោះអាចប្រើប្រាស់សិទ្ធិការពារខ្លួនបាន និងដើម្បីការពារភាពយុត្តិធម៌នៃដំណើរការនីតិវិធី។

២. ឯកសារសំខាន់ៗ ត្រូវរាប់បញ្ចូលទាំងសេចក្តីសម្រេចណាដែលដកហូតសេរីភាពរបស់គាត់ បទចោទ ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ និងសាលក្រម។

៣. អាជ្ញាធរមានសមត្ថកិច្ច នៅក្នុងរឿងក្តីណាមួយ ត្រូវសម្រេចថាតើឯកសារណាផ្សេងទៀតដែលសំខាន់។ ជនសង្ស័យ ឬជនជាប់ចោទ ឬមេធាវីរបស់គាត់ អាចដាក់សំណើដោយមានសំអាងហេតុចំពោះបញ្ហានោះ។

៤. មិនត្រូវមានលក្ខខណ្ឌតម្រូវត្រូវបកប្រែខ្លឹមសារ នៃឯកសារសារសំខាន់ៗដែលមិនពាក់ព័ន្ធនឹងគោលបំណងឲ្យជនសង្ស័យ ឬជនជាប់ចោទ អាចដឹងឮអំពីរឿងក្តីចោទគាត់ឡើយ។

១៣. អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ក៏លើកឡើងផងដែរអំពីសិទ្ធិទទួលបានការបកប្រែជាលាយល័ក្ខណ៍អក្សរ និងការបកប្រែផ្ទាល់មាត់នៅមាត្រា ៨(២)(ក) ៖

> ៨(២)[...] នៅក្នុងអំឡុងពេលដំណើរការនីតិវិធី ជនគ្រប់រូបមានសិទ្ធិដោយស្មើភាពគ្នាពេញលេញទទួលបានការធានាជាអប្បបរមាដូចខាងក្រោម៖
>
> (ក) សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានជំនួយការដោយឥតគិតថ្លៃពីអ្នកបកប្រែជាលាយល័ក្ខណ៍អក្សរ ឬអ្នកបកប្រែផ្ទាល់មាត់ ប្រសិនបើគាត់មិនយល់ ឬមិនចេះនិយាយភាសារបស់សាលាក្តី ឬតុលាការ [...]។

01302773



១៤. ខ្ញុំមិនអាចរកឃើញសេចក្តីសម្រេចណាមួយស្តីពីបទប្បញ្ញត្តិនេះដែលចេញដោយតុលាការសិទ្ធិមនុស្សអន្តរអាមេរិក ឬមតិយោបល់ណាផ្សេងទៀតទាក់ទងនឹងការបកប្រែផ្ទាល់មាត់ឡើយ។

១៥. ជាចុងក្រោយ មាត្រា ៦៧(ច)នៃលក្ខន្តិកៈទីក្រុងរ៉ូម មានចែងពីការដាក់កំហិតស្រដៀងគ្នានេះដែរ៖

> (ច) ត្រូវមានជំនួយការ ដោយឥតគិតថ្លៃ នូវអ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព ហើយការបកប្រែនោះ*ចាំបាច់ដើម្បីឲ្យបំពេញបានតាមលក្ខខណ្ឌតម្រូវនៃភាពយុត្តិធម៌* ប្រសិនបើដំណើរការជម្រះរឿងក្តី ឬឯកសារណាមួយដែលបានបង្ហាញដល់តុលាការមិនធ្វើឡើងជាភាសាដែលជនជាប់ចោទ យល់ និងនិយាយបានយ៉ាងពេញលេញទេនោះ [គូសបញ្ជាក់បន្ថែម]។

១៦. ដោយផ្អែកលើមូលដ្ឋាននេះ ខ្ញុំមិនជឿថា មាស មុត មានសិទ្ធិទទួលបានការបកប្រែ ជាលាយល័ក្ខណ៍អក្សរនូវឯកសារដែលបានស្នើនៅក្នុងសំណើ ដោយ អ.វ.ត.ក ជាអ្នកចំណាយឡើយ។

១៧. បន្ថែមពីលើនេះទៀត ក្នុងបរិបទដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ចំពោះមេធាវី គេអាចព្យាករថា នៅពេលដែលតំណាងកូនក្តីរបស់ខ្លួន អាចចាំបាច់ត្រូវពិគ្រោះជាមួយប្រភពជាភាសាផ្សេងក្រៅពីភាសាដែលសមាជិកនៃក្រុមមេធាវីការពារក្តី និយាយ។ ហេតុនេះ ក៏ស្ថិតនៅក្នុងរង្វង់នៃការទទួលខុសត្រូវរបស់មេធាវីប្រកបវិជ្ជាជីវៈនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវទុកមួយឡែកនូវថវិកាដែលអាចត្រូវប្រើប្រាស់សម្រាប់ការបកប្រែបែបនោះ។

១៨. នៅពេលដែលប្រាស្រ័យទាក់ទងជាមួយនឹងអង្គភាពគាំពារការការពារក្តី ខ្ញុំបានដឹងថា ថវិការបស់មេធាវីការពារក្តី មិនមានប្រាក់បម្រុងពេញលេញសម្រាប់ការចំណាយលើបុគ្គលិកឡើយ ហើយ អង្គភាពគាំពារការការពារក្តី អាចមានថវិកាបន្ថែមទុកដោយឡែកសម្រាប់ការងារបកប្រែជាលាយល័ក្ខណ៍អក្សរ។ បន្ថែមពីលើនេះទៀត ខ្ញុំក៏ដឹងថា សហមេធាវី ទទួលបានប្រាក់កម្រៃសរុបរួមប្រចាំខែ ដែលមិនមានការបម្រុងទុកផងដែរសម្រាប់ការចំណាយជាក់លាក់ណាមួយចំពោះចំណាយរដ្ឋបាលទូទៅ។

១៩. ជាចុងក្រោយ ខ្ញុំក៏បានដឹងថា អង្គភាពបកប្រែភាសា មានលទ្ធភាពផ្តល់ការបកប្រែជាលាយល័ក្ខណ៍អក្សរពីភាសាផ្សេងៗក្រៅពីភាសាខ្មែរ និងភាសាបារាំង ទៅជាភាសាអង់គ្លេស ប្រសិន

បើមានការស្នើ។

២០. ហេតុនេះ មេធាវីការពារក្តី គួរតែប្រើប្រាស់ថវិកាដែលខ្លួនអាចចំណាយ ដើម្បីទទួលបានការបកប្រែឯកសារដែលបានបង្ហាញនៅក្នុងសំណើ។

ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

២១. **បដិសេធ** សំណើ។

ភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**